# ធានារ៉ាប់រងដែល បង្កើតឡើង ដើម្បីអ្នក




## ហេតុអ្វីត្រូវជ្រើសរើស ហ្វតតេ?

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេនៅកម្ពុជា ហ្វតតេ ធានាចំពោះលោកអ្នកថា លោកអ្នកនឹងទទួលបាននូវសេវាធានារ៉ាប់រងដែលគ្រប់ជ្រុងជ្រោយ និង ទុកចិត្តបាន ដោយហ្វតតេផ្តោតសំខាន់លើ ៖

- បុគ្គលិកប្រកបដោយវិជ្ជាជីវៈ
- ផលិតផល និង សេវាកម្មដែលមានលក្ខណៈច្នៃប្រឌិតខ្ពស់ និង ស្របទៅតាមតម្រូវការរបស់លោកអ្នក
- ដំណោះស្រាយចំពោះការទាមទារសំណងរហ័សទាន់ចិត្ត
- សេវាកម្មដោះស្រាយសំណងមានប្រសិទ្ធភាពខ្ពស់ជាមួយអ្នកឯកទេសរបស់យើង
- ស័ក្តិសមទៅនឹងថវិកាដែលលោកអ្នកចំណាយ
- សុវត្ថិភាពហិរញ្ញវត្ថុជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងបន្ត
- ការយកចិត្តទុកដាក់លើអតិថិជនក្នុងស្រុក
- អ្នកផ្តល់ប្រឹក្សាតាមច្រើនភាសា
- ទូរស័ព្ទទំនាក់ទំនង24 ម៉ោងសម្រាប់ហេតុការណ៍បន្ទាន់

ជាមួយក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ បុគ្គលិកដែលមានជំនាញ និង វិជ្ជាជីវៈរបស់យើងនឹងព្យាយាមយល់ពីតម្រូវការរបស់លោកអ្នក ហើយរៀបចំប័ណ្ណសន្យារ៉ាប់រងដែលសមស្របបំផុតសម្រាប់លោកអ្នក និង អាជីវកម្ម។ ហេតុនេះហើយទើបអតិថិជនកាន់តែច្រើនជឿជាក់លើ ហ្វតតេ ហើយនេះក៏ជាវិធីសាស្ត្រដែល
«យើងកសាងទំនុកចិត្ត»។

ហ្វតតេ ផ្តល់ផលិតផល និង សេវាកម្មជាច្រើនដូចជា ៖

ផ្នែកបុគ្គល
- យានយន្ត
- គ្រោះថ្នាក់បុគ្គល
- ដំណើរទេសចរណ៍
- សុខភាព
- គេហដ្ឋាន និង ទ្រព្យសម្បត្តិ

ផ្នែកហិរញ្ញវត្ថុ
- ភារៈទទួលខុសត្រូវរបស់នាយកក្រុមហ៊ុន
- ភារៈទទួលខុសត្រូវវិជ្ជាជីវៈ
- ធនាគារ

ផ្នែកអាជីវកម្មខ្នាតតូច និង មធ្យម
- មិត្តអាជីវកម្ម

ផ្នែកអាជីវកម្ម
- ទ្រព្យសម្បត្តិ
- ការខាតបង់ប្រាក់ចំណេញ
- ភារៈទទួលខុសត្រូវតតិយជន
- ចោរលួច
- គ្រោះថ្នាក់ និង សុខភាព
- ហិរញ្ញវត្ថុ
- ភាពស្មោះត្រង់របស់បុគ្គលិក
- ដឹកជញ្ជូនទំនិញ
- សំណង់ និង វិស្វកម្ម
- ធានារ៉ាប់រងលើនិស្សិត

ព្រមទាំងផលិតផល និង សេវាកម្មដទៃទៀតតាមការស្នើសុំ។

មិត្តអាជីវកម្ម ត្រូវបានបង្កើតឡើង និង ផ្តល់ការធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ (កម្ពុជា) ភីអិលស៊ី។

កំណត់ចំណាំសំខាន់៖

1. ខិត្តប័ណ្ណនេះមិនមែនជាកិច្ចសន្យាធានារ៉ាប់រងទេ។ លក្ខខណ្ឌច្បាស់លាស់សម្រាប់ធានារ៉ាប់រងនេះមាននៅក្នុងប័ណ្ណសន្យារ៉ាប់រង ដែលនឹងផ្តល់ជូនបានតាមការស្នើសុំ។ យើងក៏ការនឹងផ្តល់ជូនលោកអ្នកនូវសេចក្តីលម្អិត និង លក្ខខណ្ឌផ្សេងៗក្នុងប័ណ្ណសន្យារ៉ាប់រង។
2. អត្ថប្រយោជន៍ធានារ៉ាប់រងនឹងផ្តល់ជូនទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប័ណ្ណសន្យារ៉ាប់រង។
3. លទ្ធភាពនៃការផ្តល់ការធានារ៉ាប់រង គឺអនុលោមទៅតាមច្បាប់ និង ការសម្រេចចិត្តរបស់ Underwriter។


## ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ (កម្ពុជា) ភីអិលស៊ី

ភ្នំពេញ
អគារលេខ 325 មហាវិថីម៉ៅសេទុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (855) 023 885 066 / 077
ទូរសារ: (855) 023 986 922 / 882 798
អ៊ីមែល: info@forteinsurance.com

សៀមរាប
មណ្ឌលស្អាតចាស់ ភូមិសាលាកន្សែង ឃុំស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កម្ពុជា (ខាងជើងទល់មុខសាលាមន្ទីរជាតិ)
ទូរស័ព្ទ: (855) 063 963 355
ទូរសារ: (855) 063 963 610
អ៊ីមែល: srp@forteinsurance.com

## ធានារ៉ាប់រងអាជីវកម្មរបស់លោកអ្នក

### អាជីវកម្មរបស់លោកអ្នកនឹងដំណើរការជានិច្ច

ហាងដែលពោរពេញដោយអតិថិជន គឺជាគោលបំណងរបស់លោកអ្នក។ ប៉ុន្តែនៅពេលដែលផលិតផលល្អ និង គំនិតទីផ្សារទាន់សម័យស្ថិតនៅក្នុងដៃលោកអ្នក ហេតុការណ៍ដែលមិនអាចគ្រោងទុកនៅតែអាចកើតឡើងនិងប៉ះពាល់ដល់អាជីវកម្មរបស់លោកអ្នក។ បើលោកអ្នកមិនមានការការពារសមស្របទេ អាជីវកម្មរបស់លោកអ្នកនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរ។ **មិត្តអាជីវកម្ម** គឺជាសេវាធានារ៉ាប់រងថ្មីមួយដែលអាចផ្តល់ជូនលោកអ្នកនូវការធានាសមស្របរួមជាមួយនឹងតម្លៃសមរម្យ។ លោកអ្នកអាចរៀបចំប័ណ្ណសន្យារ៉ាប់រង ដែលស័ក្តិសមទៅនឹងតម្រូវការអាជីវកម្មរបស់លោកអ្នកដោយខ្លួនអ្នកផ្ទាល់។

### ការធានាដែលបត់បែនតាមតម្រូវការ

លោកអ្នកអាចជ្រើសយកធានារ៉ាប់រងចាំបាច់ ដើម្បីធានាអចលនទ្រព្យរបស់លោកអ្នកទប់ទល់នឹងហានិភ័យគ្រប់យ៉ាង និង ផ្តល់ការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុពេលមានហេតុការណ៍ចាំបាច់។ បន្ថែមពីនេះ លោកអ្នកក៏មានសិទ្ធិក្នុងការជ្រើសយកធានារ៉ាប់រងតាមចំណង់ចិត្តណាមួយ ដើម្បីទទួលបានការធានារ៉ាប់រងគ្រប់ជ្រុងជ្រោយ។

## ធានារ៉ាប់រងចាំបាច់

### អគ្គិភ័យ និង ហានិភ័យផ្សេងៗ

អាជីវកម្មរបស់លោកអ្នកនឹងត្រូវបានការពារ ទប់ទល់នឹងការបាត់បង់ ឬ ខូចខាតចំពោះអគារ គ្រឿងសង្ហារិម បរិក្ខារ ម៉ាស៊ីន សម្ភារៈប្រើប្រាស់ និង ទំនិញផ្សេងៗ។ លោកអ្នកក៏នឹងទទួលបានការធានាបន្ថែមទៀត ដូចជា ថ្លៃពន្លត់អគ្គិភ័យ ថ្លៃប្រមូលកម្ទេចកម្ទី និង ការចំណាយផ្សេងៗទៀតជាច្រើន។

### ធានារ៉ាប់រងឥតគិតថ្លៃ – ការខាតបង់ប្រាក់ចំណេញ

លោកអ្នកនឹងទទួលបានការធានាបន្ថែមដោយឥតគិតថ្លៃចំពោះការខាតបង់ប្រាក់ចំណេញ នៅពេលអាជីវកម្មជួបប្រទះនឹងហានិភ័យខាងលើ។

## ធានារ៉ាប់រងតាមចំណង់ចិត្ត

### ភារៈទទួលខុសត្រូវលើតតិយជន

គ្រោះថ្នាក់អាចកើតមានគ្រប់ពេល និង គ្រប់ទីកន្លែង។ ធានារ៉ាប់រងនេះនឹងការពារលោកអ្នកចំពោះភារៈទទួលខុសត្រូវលើតតិយជន ដែលពួកគេអាចនឹងរងរបួស ឬខូចខាតទ្រព្យសម្បត្តិនៅទីតាំងអាជីវកម្មរបស់អ្នក។

### គ្រោះថ្នាក់បុគ្គល

ធានារ៉ាប់រងនេះនឹងផ្តល់ការធានាដល់លោកអ្នក និង បុគ្គលិករបស់លោកអ្នកពេញ 24 ម៉ោងជុំវិញពិភពលោក សម្រាប់មរណភាព ពិការភាព និង ការចំណាយសម្រាប់ការព្យាបាល ដែលបង្កឡើងដោយសារគ្រោះថ្នាក់។



តម្រូវការធានារ៉ាប់រងមានភាពខុសគ្នា

## ការរៀបរាប់ពីការធានារ៉ាប់រង និង អត្ថប្រយោជន៍បន្ថែម

| ធានារ៉ាប់រងចាំបាច់ | កម្រិតនៃការធានា (ដុល្លារ) | បុព្វលាភ (ដុល្លារ) |
|---|---|---|
| **ផ្នែកទី 1: អគ្គិភ័យ និង ហានិភ័យផ្សេងៗ** | | |
| 1) អគ្គិភ័យ<br>2) ផ្លេរ<br>3) ការខូចខាតបណ្តាលពីយន្តហោះ<br>4) ការផ្ទុះបែកបំពង់ទឹក<br>5) ខ្យល់ព្យុះ និង បន្ទុះផ្គររន្ទះ<br>6) ការផ្ទុះ<br>7) ទឹកជំនន់<br>8) ការខូចខាតពីការបុកប៉ះ<br>9) ការខូចខាតដោយសារផ្សែង<br>10) ការលួចបាតដោយបង្ខំ<br><br>**អត្ថប្រយោជន៍បន្ថែម (ឥតគិតថ្លៃ):**<br>1) សម្ភារៈផ្សេងៗ (រហូត 1,000 ដុល្លារ)<br>2) ការធានាពេលផ្ទេរសម្ភារៈ<br>3) ការធានាបំពេញឡើងវិញដោយស្វ័យប្រវត្តិ<br>4) ថ្លៃពន្លត់អគ្គិភ័យ (រហូត 500 ដុល្លារ)<br>5) ថ្លៃប្រមូលកម្ទេចកម្ទី (រហូត 5% នៃសំណងសរុប) | ជម្រើសទី1: USD 25,000<br>ជម្រើសទី2: USD 50,000<br>ជម្រើសទី3: USD 100,000<br>ជម្រើសទី4: USD 150,000<br>ជម្រើសទី5: USD 200,000<br>ជម្រើសទី6: USD 250,000<br><br>Excess សម្រាប់<br>ជម្រើសទី1: USD 200<br>ជម្រើសទី2: USD 250<br>ជម្រើសទី3: USD 500<br>ជម្រើសទី4: USD 750<br>ជម្រើសទី5: USD 1,000<br>ជម្រើសទី6: USD 1,250<br><br>Excess គឺសម្រាប់រាល់ការទាមទារសំណង | 35<br>70<br>140<br>210<br>280<br>350 |
| **ការធានាបន្ថែមឥតគិតថ្លៃ** | | |
| ការខាតបង់ប្រាក់ចំណេញ | 3% នៃសំណងសរុបសម្រាប់គ្រប់ការទាមទារសំណងក្នុងផ្នែកទី1 | ឥតគិតថ្លៃ |
| **ធានារ៉ាប់រងតាមចំណង់ចិត្ត** | **កម្រិតនៃការធានា (ដុល្លារ)** | **បុព្វលាភ (ដុល្លារ)** |
| **ផ្នែកទី2: ភារៈទទួលខុសត្រូវលើតតិយជន** | | |
| ធានារ៉ាប់រងរាល់ការទាមទារសំណងពីតតិយជន ដែលជាភារៈទទួលខុសត្រូវរបស់លោកអ្នកចំពោះការរងរបួស ឬ ខូចខាតទ្រព្យសម្បត្តិរបស់តតិយជន ដោយសារអាជីវកម្មរបស់លោកអ្នក។<br><br>**អត្ថប្រយោជន៍បន្ថែមឥតគិតថ្លៃ**<br>1) ការសង្គ្រោះបឋម<br>2) ការលើកតាំង និង ឡាន<br>3) ស្លាកផ្សាយពាណិជ្ជកម្ម | ជម្រើសទី1: USD 25,000<br>ជម្រើសទី2: USD 50,000<br>ជម្រើសទី3: USD 100,000<br>ជម្រើសទី4: USD 150,000<br>ជម្រើសទី5: USD 200,000<br>ជម្រើសទី6: USD 250,000<br><br>កម្រិតនៃការធានាគឺសម្រាប់ករណីណាមួយ និង សរុបទាំងអស់។<br><br>Excess = USD 250 ដុល្លារ សម្រាប់រាល់ការទាមទារសំណងលើការខូចខាតទ្រព្យសម្បត្តិតតិយជន។ | 25<br>50<br>100<br>150<br>200<br>250 |
| **ផ្នែកទី 3: គ្រោះថ្នាក់បុគ្គល** | | |
| A. មរណភាពដោយសារគ្រោះថ្នាក់<br>B. ពិការភាពដោយសារគ្រោះថ្នាក់<br>C. ការចំណាយសម្រាប់ព្យាបាលរបួសដោយសារគ្រោះថ្នាក់ = 10% នៃកម្រិតនៃការធានាសម្រាប់ 1 ករណី និង ក្នុងរយៈពេលធានារ៉ាប់រង។<br><br>**អត្ថប្រយោជន៍បន្ថែម (ឥតគិតថ្លៃ):**<br>1) ការផ្លាស់ប្តូរបុគ្គលិកដោយស្វ័យប្រវត្តិ<br>2) ថវិកាចូលរួមរំលែកមរណទុក្ខ<br>3) ពស់ចឹក ឬ សត្វល្អិតខាំ | ជម្រើសទី1: USD 2,000<br>ជម្រើសទី2: USD 5,000<br>ជម្រើសទី3: USD 10,000<br>ជម្រើសទី4: USD 15,000<br>ជម្រើសទី5: USD 20,000<br>ជម្រើសទី6: USD 25,000<br><br>150 ដុល្លារចំពោះមរណភាពមិនមែនមកពីគ្រោះថ្នាក់ | 5<br>12.5<br>25<br>37.5<br>50<br>62.5<br><br>បុព្វលាភសម្រាប់ម្នាក់ៗ |

# ដំណោះស្រាយធានារ៉ាប់រង ដែលស័ក្តិសមជាមួយលោកអ្នក



### អាជីវកម្មដែលមិនផ្តល់ការធានារ៉ាប់រង

| | |
|---|---|
| 1) វត្ថុបុរាណវត្ថុសិល្បៈ | 11) អ្នកផ្ទុះលុយ |
| 2) គ្រឿងបន្លាស់យានយន្ត | 12) ឃ្លាំងស យានយន្ត |
| 3) អាគុយ និង កង់យានយន្ត | 13) ហាងថ្នាំ ចាញ់ថ្នាំ ប៉ូលា |
| 4) កន្លែងភ្នាល់ផ្សេងៗ | 14) ហាងបញ្ចាំ |
| 5) ថ្នាំបុរាណចិន | 15) ព្រៃយក្រីឡាម សម្លៀកបំពាក់ចៀកកាំ |
| 6) គ្រឿងអលង្ការ | 16) របស់ដែលងាយឆាបឆេះ |
| 7) របស់ផ្ទុះ | 17) បារី ស្រា |
| 8) ឈ្នួលក់តាមចិញ្ចើមថ្នល់ | 18) នាឡិកា |
| 9) ប្រេងសាំង ឧស្ម័ន | 19) ទ្រព្យសម្បត្តិដែលគ្មានការការពារ |
| 10) ឈ្នួលក់តាមផ្សារ | |

បាន/ចាស! អាជីវកម្មរបស់ខ្ញុំសមស្របនឹងលក្ខខណ្ឌខាងក្រោម៖

- សំណង់ប្រភេទទី 1 (សង់ពីឥដ្ឋ ជញ្ជាំងបេតុង និង ប្រក់ដំបូលដែលមិនងាយឆាបឆេះ)
- អគារមានអាយុតិចជាង 20 ឆ្នាំ
- គាត់កាប់ពេញពីតម្លាក់ឯង
- គ្មានការទាមទារសំណងរយៈពេល3 ឆ្នាំកន្លងមក
- មានបំពង់ពន្លត់អគ្គិភ័យយ៉ាងតិច1 ឬ sprinkler system
- ប្រកបដោយគោលត្រូវបានការពារដោយទ្វារមុខ/ទ្វារកញ្ចក់/បង្អួចដែក និង សោ។

បុព្វលាភតិចបំផុត៖ 50 ដុល្លារ
ថ្លៃតែមប្រាម៖ 1 ដុល្លារ